# *អ្វីទៅជាសៀវភៅមគ្គុទ្ទេស ចំពោះការបរិភោគត្រីស្ទូចលេង នៅ អនធារីយ៉ូ?*

*សៀវភៅមគ្គុទ្ទេសចំពោះការបរិភោគត្រីស្ទូចលេងនៅអនធារីយ៉ូ* (*មគ្គុទ្ទេស*) ជាការបោះពុម្ពផ្សាយជាសធារណៈនៃរដ្ឋអនធារីយ៉ូ ដោយឥតគិតថ្លៃដែលផ្តល់ឱវាទនូវរបៀបដល់អ្នកស្ទូច និងអ្នកទាំងឡាយដែលបរិភោគ ដែលពួកគេស្ទូចបានដោយគ្មានគ្រោះថ្នាក់ ។ វិធានការកាពារទាំងនេះតម្រូវឱ្យមានព្រោះ បច្ចុប្បន្នកាលភាពក្រខ្វក់នៃបរិយាការមាននៅក្នុងត្រីខ្លះៗ ។

ទោះជាមានសារៈសំខាន់ដល់អ្នករាល់គ្នាធ្វើតាមឱវាទនៅក្នុង*សៀវភៅមគ្គុទ្ទេស* ក៏ដោយវាសំខាន់ជាង

គេណាស់ចំពោះស្រ្តីក្នុងវ័យបង្កើតកូន និង ក្មេងអាយុក្រោម ១៥ ឆ្នាំ ។ ក្រុមមនុស្សនេះធាប់ប៉ះទង្គិចជាងអ្នកឯទៀត ចំពោះភាពក្រខ្វក់ដែល រកឃើញនៅក្នុងត្រី ។




ភាគច្រើនត្រីបានប្រមូលឱ្យគណៈកម្មកានៃក្រសួង ធម្មជាតិ ហើយត្រូវបានពិសោធមើលដោយ ក្រសួងនៃក្រសួងបរិយាការ ។

ក្រុមប្រឹក្សាអនុមត្តឱ្យប្រើត្រីគឺផ្អែកទៅលើគោលការណែនាំដែលបង្កើតឡើងដោយក្រសួងសុខាភិបាល កាណាដា ។ ឱវាទដែលមានទៅក្នុង*សៀវភៅមគ្គុទ្ទេស*យោលទៅលើកំរិតនៃភាពក្រខ្វក់ដែលបានរកឃើញនៅក្នុងស្រទាប់សាចត្រី តែមិននៅក្នុងផ្នែកផ្សេងៗទេដូចជាស្បែក ថ្លើម គ្រឿងក្នុង ឬពងត្រីឡើយ ។ *សៀវភៅមគ្គុលទ្ទេស*ផល់ឱវាងឱ្យប្រើប្រាស់ប្រភេទត្រីស្ទូចលេងទូរទៅភាគច្រើនពិជាង ១៧00 កន្លែងនៅ អនធារីយ៉ូ ។

ដើម្បីទទួលច្បាប់នៃ*សៀវភៅមគ្គុលទ្ទេស*ជាភាសារអង់ឃ្លេស និង បារាំងដោយមិនគិតថ្លៃ ឬ បើលោកអ្នកមានចម្ងល់ផ្សេងទៀត សូមអញ្ជើញទាក់ទងទៅគណៈកម្មការបរិយាការប្រ៉ក្រាមត្រួតពិនិត្យការក្រខ្វក់នៃត្រីស្ទូចលេងតាមលេខ **416-327-6816** ឬ តាមទូរសព្ទមិនបង់ថ្លៃនៅ អនធារីយ៉ូលេខ **1-800-820-2716** ឬ សរសេរសំបុត្រទៅអស័យដ្ឋាននៅទំព័រក្រោយ ។

## ការប្រើ *សៀវភៅមគ្គុទ្ទេស* ៖

*សៀវភៅមគ្គុលទ្ទេស*បានបែងចែកជាសំបន់ អនធារីយ៉ូខាងត្បូង តំបន់ អនធារីយ៉ូខាងជើង និងតំបន់បឹងគ្រេតលេក (Great Lakes) ។

តាមទីកន្លែលនិមួយៗ ឱវាតនៃការប្រើត្រីបានផ្តល់ឱ្យរាប់ត្រីទូរទៅជាច្រើនប្រភេទដែលបានរកឃើញតាមបឹងនិងទន្លេតាមកន្លែងនិមួយៗ ។ ក្រោយអ្នកចាប់ត្រីបានវាស់ត្រីពី ក្បាលដល់កន្ទុយ ។ ដើម្បីជួយអ្នកឱ្យស្គាល់ច្បាស់ពីការចាប់ត្រីបានរបស់ អ្នក ចូរមើលការពន្យល់ប្រាស់នៅទំព័កណ្តាល ។

ចូរមើលតារាងប្រើប្រាស់ត្រី ដើម្បីរកមើលកន្លែងណាមួយ ដែលត្រីបានចាប់មក ។

Ontario

តារាងប្រើប្រាស់ត្រី (ឧទាហរណ៍ បង្ហាញខាងក្រោម) ប្រាប់ពីទីកន្លែងប្រភេទនិងទំហំត្រី ។ ឱវាទប្រើប្រាស់ត្រីសំរាប់ប្រភេទនិមួយៗមានពីបន្ទាត់ ។ បន្ទាត់ទីមួយសំរាប់ពលរដ្ឋទូរទៅ បន្ទាត់ទីពីរសំរាប់ពលរដ្ឋដែលឆាបប៉ះទង្គិច ជាស្ត្រីក្នុងវ័យបង្កើតកូន និង ក្មេងអាយុក្រោម ១៥ ឆ្នាំ ។

លេខដែលក្រោមទំហំកំណត់ត្រឹមត្រូវបង្ហាញពីចំនួននៃពេលបរិភោគនៃទំហំត្រីដែលចាប់បាននៅតំបន់នោះ ដែលអ្នកបរិភោគមួយខែៗ ។ បើអ្នកមិនបរិភោគត្រីស្ទូចលេង ក្រៅពីទំហំកំណត់ប្រភេទ និង ពីចំនួនអតិបរិមាណនៃពេលបរិភោគត្រីដែលអ្នកប្រើប្រាស់ក្នុងមួយខែ ។

<table>
<tr><td>Length/<br>Longueur</td><td>15<br>6"</td><td>20<br>8"</td><td>25<br>10"</td><td>30<br>12"</td><td>35<br>14"</td><td>40<br>16"</td><td>45<br>18"</td><td>50<br>20"</td><td>55<br>22"</td><td>60<br>24"</td><td>65<br>26"</td><td>70<br>28"</td><td>75<br>30"</td><td>>75 cm<br>>30"</td></tr>
<tr><td colspan="15">Emily Lake / Lac Emily<br>Sauger Twp./Canton de Sauger, Sturgeon Co./Cté de Sturgeon 4537/7942</td></tr>
<tr><td>Northern Pike[5]</td><td></td><td></td><td></td><td colspan="5">8</td><td colspan="6">4</td></tr>
<tr><td>Brochet[5]</td><td></td><td></td><td></td><td>8</td><td colspan="3">4</td><td colspan="7">0</td></tr>
<tr><td>Walleye[5]</td><td></td><td></td><td></td><td>8</td><td colspan="5">4</td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>Doré[5]</td><td></td><td></td><td></td><td>4</td><td colspan="5">0</td><td></td><td></td><td></td><td></td><td></td></tr>
</table>

## ការប្រើប្រាស់ត្រីលើសពីមួយទំហំមួយប្រភេទ ឬ មួយតំបន់

បើអ្នកបរិភោគត្រីលើសពីមួយទំហំកំណាត់ មួយប្រភេទ ឬ មួយតំបន់ នោះអ្នកត្រូវតែបន្ថែមចំនួនប្រភាគលើចំនួនរួម ពីពេលបាយដែលអ្នកបរិភោគប្រចាំខែ ។

ចំនួនប្រភាគនៃចំនួនរួមប្រចាំខែ ពីពេលបរិភោគនិមួយៗដែលបានប្រើក្នុងអំឡុងមួយខែ បានបង្ហាញប្រាប់ខាងក្រោម ចំនួនរួម ពីពេលបរិភោគទាំងអស់មិនគួរហួសពីមួយទេ (ចូរមើលនៅទំព័រទី ២ នៃ*សៀវភៅមគ្គុទ្ទេស*)

| លេខក្នុងតារាងប្រើប្រាស់ | ឱវាទ | ប្រភាគនៃចំនួនរួមប្រចាំខែ |
|---|---|---|
| 8 | ការប្រើប្រាស់ដល់ 8 ពេលក្នុងមួយខែ | 1/8 |
| 4 | ការប្រើប្រាស់ដល់ 4 ពេលក្នុងមួយខែ | 1/4 |
| 2 | ការប្រើប្រាស់ដល់ 2 ពេលក្នុងមួយខែ | 1/2 |
| 1 | ការប្រើប្រាស់ដល់ 1 ពេលក្នុងមួយខែ | 1 |
| 0 | ឥតបានប្រើប្រាស់សោះ | – |

## ការប្រើប្រាស់ហាងទិញត្រីនិងត្រីស្ទូចលេង

ត្រីដែលទិញពីហាងលក់ រាយត្រូវបានសាកមើលដោយភ្នាក់ងាពិនិត្យអាហារ កាណាដា ដើម្បីឱ្យដឹងច្បាក់ថាវាបានត្រឹមត្រូវតាមលក្ខ័ណ កាណាដា ។ ភាគច្រើនមានភាពក្រខ្វក់ទាបតែបើទូទៅអ្នកប្រើហាងទិញត្រីហើយមាន បំណងចក់បរិភោគត្រីស្ទូចលេង អ្នកប្រហែលត្រូវបន្ថយការកំណត់ឱ្យ ប្រើត្រីស្ទូចលេងរបស់អ្នក ។ ចូរអាននៅទំព័រទី ៧ ក្នុង*សៀវភៅមគ្គុទ្ទេស*សំរាប់ឱវាទច្បាស់លាស់ ។

## មានពតិមានបន្ថែតទៀតដោយទាក់ទងទៅ ៖

Sport Fish Contaminant Monitoring Program
Ministry of the Environment
125 Resources Road
Etobicoke, ON M9P 3V6
ទូរសព: 416-327-6816 ឬ 1-800-820-2716
E-mail: sportfish.moe@ontario.ca
www.ontario.ca/fishguide

© 2007 Queen's Printer for Ontario PIBS#: 4395q02